# សមាគមធានារ៉ាប់រងកម្ពុជា
Insurance Association of Cambodia

## ខ្លឹមសារសង្ខេបនៃសិក្ខាសាលា ស្តីពី
## “ទីផ្សារធានារ៉ាប់រង និងឱកាសការងារ” លើកទី ១






នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ សមាគមធានារ៉ាប់រងកម្ពុជា បានរៀបចំសិក្ខាសាលា ស្តីពី “ទីផ្សារធានារ៉ាប់រង និងឱកាសការងារ” នៅសាកលវិទ្យាល័យបៀលប្រាយ ក្រោមការចូលរួមជាអធិបតីរបស់លោកបណ្ឌិត **សួង ច័ន្ទនាង** នាយកប្រតិបត្តិនៃសាកលវិទ្យាល័យ បៀលប្រាយ និងដោយមានវាគ្មិនមកពីក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក ចូលរួមចែករំលែក ចំណេះដឹង និងបទពិសោធន៍ថ្មីៗ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីវិស័យធានារ៉ាប់រង ដល់សិស្សនិស្សិតនៅកម្ពុជា។ ថ្លែងក្នុងពិធីបើកសិក្ខាសាលា លោកបណ្ឌិត **សួង ច័ន្ទនាង** នាយកប្រតិបត្តិនៃសាកលវិទ្យាល័យបៀលប្រាយ មានប្រសាសន៍ថា លោកមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលសមាគមធានារ៉ាប់រងនៃកម្ពុជា បានជ្រើសរើសសាកលវិទ្យាល័យរបស់លោកដើម្បីរៀបចំសិក្ខាសាលានេះ ហើយក៏អរគុណដល់វាគ្មិនទាំងអស់ដែលចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការធ្វើបទបង្ហាញ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ថ្មីៗ ក៏ដូចជាការផ្តល់នូវព័ត៌មានអំពីឱកាសការងារ ដែលទាក់ទងទៅនឹងវិស័យធានារ៉ាប់រងជូនដល់សិស្សនិស្សិតទាំងអស់។

ថ្លែងក្នុងមតិស្វាគមន៍ លោក **ហ៊ុយ វ៉ាថារ៉ូ** ប្រធានសមាគមធានារ៉ាប់រងកម្ពុជា មានប្រសាសន៍ថា វិស័យធានារ៉ាប់រងត្រូវបានចាត់ទុកជាសសរស្តម្ភមួយនៃវិស័យហិរញ្ញវត្ថុ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១ - ២០២០ ហើយដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការធ្វើបច្ចុប្បន្នភាព។ ប៉ុន្តែដោយសារតែ

ភាពក្មេងខ្ចីនៃវិស័យធានារ៉ាប់រងរបស់កម្ពុជាយើង កង្វះបុគ្គលិកវិជ្ជាជីវៈក្នុងស្រុក គឺជាបញ្ហាប្រឈមមួយ។ លោកបន្ថែមទៀតថា សមាគមធានារ៉ាប់រងកម្ពុជា បាននិងកំពុងប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីរៀបចំឲ្យបុគ្គលិកធានារ៉ាប់រងវិជ្ជាជីវៈក្នុងស្រុក មានឱកាសបង្កើនចំណេះដឹងជំនាញរបស់ខ្លួនលើគ្រប់ផ្នែក នៃខ្សែសង្វាក់អាជីវកម្មធានារ៉ាប់រង។ ដូច្នេះលោកសូមលើកទឹកចិត្ត សិស្សនិស្សិតទាំអស់ដែលមានវត្តមាននៅក្នុងសិក្ខាសាលាថ្ងៃនេះ ឲ្យយកចិត្តទុកដាក់ស្តាប់ ក្រេបយកចំណេះដឹងថ្មីៗ ដើម្បីចូលបំរើការងារក្នុងវិស័យធានារ៉ាប់រងក្នុងប្រទេសកម្ពុជាយើង។

ជាចុងបញ្ចប់លោក **ហ៊ុយ វ៉ាថារ៉ូ** សំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សាកលវិទ្យាល័យបៀលប្រាយ ដែលបានផ្តល់ទីតាំងក្នុងការរៀបចំសិក្ខាសាលា ព្រមទាំងអរគុណដល់វាគ្មិនទាំងអស់ដែលបានចំណាយពេលដ៏មានតម្លៃ រៀបចំបទបង្ហាញ និងមានវត្តមាននៅពេលនេះ និង សូមអគុណចំពោះក្រុមហ៊ុនធានារ៉ាប់រង ខេមបូឌាឡាយហ្វ៍ ដែលបានផ្តល់ជាកាដូរនិងវត្ថុអនុស្សាវរីយ៍ដល់ដល់សិស្សនិស្សិតដែលបានចូលរួមសិក្ខាសាលាថ្ងៃនេះ។ លោកសង្ឃឹមថា ការរៀបចំឲ្យមានសិក្ខាសាលាថ្ងៃនេះនឹងផ្តល់ឱកាសសម្រាប់ សិស្សនិស្សិតទាំងអស់ មិនត្រឹមតែទទួលបាននូវចំណេះដឹងថ្មីៗ ទាក់ទងនឹងវិស័យធានារ៉ាប់រងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជួយផ្តល់ជាចំនេះដឹងអំពីការប្រើប្រាស់ និងអត្ថប្រយោជន៏នៃសេវាធានារ៉ាប់រងកាន់តែទូលំទូលាយថែមទៀត។






រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៦

**សមាគមធានារ៉ាប់រងកម្ពុជា**